## មជ្ឈមណ្ឌលឯកសារកម្ពុជា

# ក្មួយប្រុសរបស់ យឹម ទិត ហៅ តាទិត
# បទសម្ភាសន៍ជាមួយឈ្មោះ ទឹម ភួន ភេទប្រុស អាយុ៤៩ឆ្នាំ
# ភូមិត្រពាំងឈូក ឃុំត្រពាំងធំត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ
# ថ្ងៃទី២២ ខែមករា ឆ្នាំ២០១១
# សម្ភាសដោយៈ ឡុង ដានី

ដានីៈ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ ឈ្មោះពេញណា?

ភួនៈ ខ្ញុំឈ្មោះ ទឹម ភួន

ដានីៈ អាយុប៉ុន្មានហើយ សព្វថ្ងៃ?

ភួនៈ អាយុ៤៩ហើយ ។

ដានីៈ ពូកើតឆ្នាំអី?

ភួនៈ ឆ្នាំថោះ ឆ្នាំ១៩៦៣ ។

ដានីៈ កំណើតកើតជាពូនៅភូមិអីឃុំស្រុកអីដែរ?

ភួនៈ កំណើតកើតជាខ្ញុំនៅត្រពាំងធំខាងត្បូងហ្នឹង ។

ដានីៈ ភូមិអីដែរ?

ភួនៈ ភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ។

ដានីៈ ស្រុកត្រាំកក់?

ភួនៈ បាទ!

ដានីៈ ចុះសព្វថ្ងៃពូរស់នៅភូមិឃុំអីដែរ?

ភួនៈ នៅភូមិហ្នឹងដែរ ។

ដានីៈ ចុះមីងគាត់ឈ្មោះអីដែរ?

ភួនៈ ឈ្មោះ មាឃ មុំ ។

ដានីៈ មីងអាយុប៉ុន្មានហើយ?

មុំៈ អាយុ៣៨ ។

ដានីៈ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ភួនៈ ខ្ញុំ ៤នាក់ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ភួនៈ ស្រី៣ ប្រុស១ ។

ដានីៈ ពូសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

ភួនៈ មុខរបរចំធ្វើស្រែ ។

ដានីៈ ហើធ្វើអីទៀត?

ភួនៈ បន្ទាប់បន្សំធ្វើគ្រឿងសង្ហារិម ។

ដានីៈ ឪពុកពូគាត់ឈ្មោះអីទៅ?

ភួនៈ ឪពុកខ្ញុំឈ្មោះ ផន ។

ដានីៈ អីផនទៅ?

ភួនៈ ឪពុកគាត់ឈ្មោះតាទឹម គាត់ឈ្មោះតា ទឹម ផន ហ្នឹង ។

ដានីៈ សព្វថ្ងៃគាត់នៅឯណាដែរ?

ភួនៈ សព្វថ្ងៃគាត់នៅស្រុកសំឡូត ភូមិសំឡូតដែរគាត់នៅ ។

ដានីៈ នៅភូមិអី?

ភួនៈ អូ! ភូមិបឹងរុន ប៉ុនមិនដឹងឃុំអីទេ ខ្ញុំអត់ស្គាល់ បែបឃុំសំឡូតហើយភូមិហ្នឹង ។

ដានីៈ ស្រុកសំឡូត?

ភួនៈ បាទ!

ដានីៈ គាត់អាយុប៉ុន្មានហើយឪពុកពូ?

ភួនៈ ឪពុកខ្ញុំ ប្រហែលជា៧២ ។

ដានីៈ ម្ដាយពូគាត់ឈ្មោះអីទៅ?

ភួនៈ ឈ្មោះ ញ៉ែម ហុង ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

ភួនៈ ម៉ែខ្ញុំ គាត់ ៧០ ។

ដានីៈ នៅជាមួយឪពុកពូដែរនៅបឹងរុន?

ភួនៈ បាទ!

ដានីៈ ចុះម្ដាយពូ គាត់មានបងប្អូនប៉ុន្មាននាក់?

ភួនៈ ម្ដាយខ្ញុំ២ ។

ដានីៈ ២នាក់!

ភួនៈ បាទ!

ដានី: មានតែពីនាក់ទេអីចឹងបងប្អូន?

ភួន: ២នាក់ហ្នឹងហើយ បានម្តាយគាត់ស្លាប់ បានតាគាត់យកយាយមួយទៀតបាន៣នាក់ទៀត ។

ដានី: អីចឹងម្តាយពូ គាត់មានបងប្អូន២នាក់! ម្នាក់ទៀតគាត់ឈ្មោះអី?

ភួន: ឈ្មោះទិត!

ដានី: គាត់ឈ្មោះអីទិតដែរ?

ភួន: ញ៉ែម! ស្គាល់តែឪពុកគាត់ ស្គាល់តែត្រឹមឪពុកគាត់ ។

ដានី: ឪពុកគាត់ឈ្មោះ...

ភួន: តាញ៉ែម ។

ដានី: ម្តាយគាត់ឈ្មោះអី?

ភួន: ឈ្មោះអីទេខ្ញុំភ្លេចទៀតណា ស្គាល់តែម្តាយចុងគាត់ក្រោយ ម្តាយមុនដឹងឈ្មោះអី អត់ដែលបានសួរគាត់ សួរនាំរឿងហ្នឹង ស្គាល់តែម្តាយចុងគាត់ ខ្ញុំកើតមកទាន់ ។

ដានី: ម្តាយចុងគាត់ឈ្មោះអី?

ភួន: ឈ្មោះភិន ។

ដានី: តាទិត គាត់អាយុប៉ុន្មានហើយសព្វថ្ងៃ?

ភួន: បងម្តាយខ្ញុំ ២ឆ្នាំ ហ្វេបងម្តាយខ្ញុំ៣,៤,៥ ឆ្នាំមិនដឹង បងនោះ ប៉ុនដាក់ប៉ុណ្ណឹងប្រហែល ស្មានមើលប្រហែលជាបង៣ឆ្នាំ ។

ដានី: អីចឹង ៧៣ អី!

ភួន: បាទ!

ដានី: អីចឹងបងប្អូនគាត់បង្កើតមានតែ២នាក់ហ្នឹងទេ មានតាទិត និងម្តាយពូឈ្មោះហុង!

ភួន: បាទ!

ដានី: ចុះម្តាយចុងមានកូនប៉ុន្មាននាក់ទៀតទៅ?

ភួន: ម្តាយចុងយកយាយហ្នុងបានកូន២ កូនយាយហ្នឹងមុនមាន២, ៣ ដែរ មានប៉ុន្មានខ្ញុំមិនដឹងដែរ ស្គាល់តែ៣ ក្រោយយកមកបានកូន២ ។

ដានី: បាន២! ឈ្មោះអីខ្លះ?

ភួន: ឈ្មោះ គួយ និងឈ្មោះ ឆែម (ឆែម ប្រុស, គួយ ស្រី) ។

ដានី: ចុះសព្វថ្ងៃគាត់នៅឯណា ២នាក់?

ភួន: អ៊ីនៅសំឡូត ពូនៅវត្តចំបា៉ ។

ដានី៖ ឈ្មោះ គួយ គាត់នៅសំឡូត!

ភួន៖ បាទ!

ដានី៖ នៅភូមិហ្នឹងដែរ ជាមួយគ្នាហ្នឹង?

ភួន៖ អត់ទេ! នៅតាសាញ់ ពូឆែម គាត់នៅវត្តចំប៉ា។

ដានី៖ វត្តចំប៉ានៅឯណាទៅ?

ភួន៖ នៅភូមិមហាសេនា។

ដានី៖ ភូមិមហាសេនា ឃុំអីហ្នុង ឃុំត្រពាំងធំ?

ភួន៖ ហ្ហូ! ឃុំតាភេម ហ្នុង។

ដានី៖ ស្រុកត្រាំកក់យើងដែរ?

ភួន៖ បាទ!

ដានី៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

ភួន៖ បងប្អូនខ្ញុំមាន១២នាក់ តែឥឡូវស្លាប់អស់៣ហើយនៅសល់៩។

ដានី៖ ១២នាក់ហ្នឹងប្រុសប៉ុន្មានស្រីប៉ុន្មានទៅ?

ភួន៖ ស្មើគ្នា ប្រុស៦ ស្រី៦។

ដានី៖ ពូកូនទីប៉ុន្មានទៅ?

ភួន៖ ខ្ញុំទី៣ បងស្លាប់អស់២នាក់ហើយ។

ដានី៖ ស្លាប់អស់៣នាក់ ស្លាប់ដោយសារមូលហេតុអី?

ភួន៖ ស្លាប់កាល៧៩ ដោយសារគេបាញ់ ទ័ពបាញ់មួយ ឆ្នាំ៨០ស្លាប់ដោយសារសម្រាលកូននៅព្រៃនោះមួយស្រី ស្លាប់ស្រីមួយ ប្រុសមួយ។

ដានី៖ ស្លាប់ដោយសារគេបាញ់ម្នាក់ សម្រាលកូនម្នាក់ ចុះម្នាក់ទៀត?

ភួន៖ ខ្ញុំអត់ទាន់អាហ្នឹង ខ្ញុំនៅរតនៈគិរី គេថាពស់ចឹក បូជាហើយណា ខ្ញុំមកពីរតនៈគិរី ស្លាប់នៅសំឡូត ប្អូនស្រី។

ដានី៖ ពូកាលពីក្មេងៗពូបានចូលសាលារៀនសូត្រអីដែរទេ?

ភួន៖ រៀនបានតិចណាស់ ខ្ញុំរៀនសាលាលើដីបូក ត្រង់សេនៅពីក្រោម រៀនឆ្នាំ៧០ជាងវាយន្តហោះទម្លាក់ ខ្ញុំរៀនក្បែរភ្នំនោះកាលហ្នុង ផ្ទះខ្ញុំនៅក្បែរភ្នំ។

ដានី៖ នៅឯណា?

ភួន៖ នៅខាងលិចនោះ ក្បែរជើងភ្នំនោះពីដើម។

ដានី: ក្បែរជើងភ្នំដីវីរមៀល?

ភួន: បាទ! រៀននៅត្រង់សេនៅពីក្រោមសាលារៀនរហូតខ្ញុំរៀន។ ខ្ញុំចូលរៀនឆ្នាំ៧១ ហីឆ្នាំ៧១ ស្រុកយើងពេញយន្តហោះទម្លាក់ ពេញសង្គ្រាមហើយកាលហ្នុង។

ដានី: ចូលរៀនឆ្នាំ៧១?

ភួន: បាទ!

ដានី: ពេលហ្នុងនៅឆ្នាំ៧១ហ្នុង នៅស្រុកភូមិយើងហ្នឹងបានន័យថាកន្លែងហ្នឹងដូចថាខាងកងទ័ពរំដោះខាងខ្មែរក្រហមគ្រប់គ្រង ឬខាងលន់ ណល់គេគ្រប់គ្រង?

ភួន: អានេះបើនិយាយទៅ វាមិនចំទេ វាប្រទាញប្រទង់ ព្រោះថាខ្មែរក្រហមវានៅក្នុងព្រៃអីចឹងទៅ ពេលណាវាមកអីចឹងទៅ វាក្នុងនេះរដ្ឋអំណាចខាងយើងនេះដែរ គ្រប់គ្រងតាមខ្ញុំដឹង ព្រោះនៅក្មេងៗណា ប៉ុន្តែខ្មែរក្រហមកម្រឃើញមក យូៗឃើញមកម្តង ចុះមក គេច្រើននៅព្រៃ នៅភ្នំជាមួយ វៀតណាម កាលហ្នុងវៀតណាមចូលមកនៅម៉ាដូរហ្នុងសុទ្ធវៀតណាមទាំងអស់។

ដានី: ចុះម៉េចបានផ្ទះពូនៅក្បែរជើងភ្នំវិញ?

ភួន: ពីដើមផ្ទះខ្ញុំនៅនេះដែរ ប៉ុនពុកខ្ញុំចេះតែកិលទៅរកដីថ្មីរហូត យូៗទៅរកដីថ្មី។

ដានី: ចុះអ្នកភូមិនៅហ្នឹង គេរំកិលទៅហ្នុងដែរឬក៏...

ភួន: បាទ! ភាគច្រើននៅលើៗ ខ្លះផ្ទះនៅនេះមែន ប៉ុន្តែដីស្រែ ដីអីចេះតែរាណដីថ្មីទៅលើ ព្រោះខ្ញុំទាន់ពេលឪពុលខ្ញុំគាត់កំពុងរាណដីថ្មី ដីព្រៃ។

ដានី: អីចឹងកាលជំនាន់ពូ គឺរៀននៅក្រោមដំបូកក្រោមអី?

ភួន: បាទ! រៀននៅកំពូលដំបូក រៀនក្នុងព្រៃម៉ង កន្លែងណាមានដំបូក ជីកត្រង់សេពីក្រោមធ្វើសាលាពីលើ។

ដានី: គេបង្រៀនយ៉ាងម៉េចទៅអីចឹង បើយើងរៀននៅកណ្តាលវាលអីចឹង?

ភួន: រៀនតាមសៀវភៅយើងពីអស់នេះទៅដែរ ប៉ុន្តែក្មេងគេអត់សូវឲ្យមកឆ្ងាយពីផ្ទះណា ពីព្រោះខ្លាចយន្តហោះ ខ្លាចអីទម្លាក់ ព្រោះយន្តហោះវាមកទម្លាក់ញឹកដែរនៅម្តុំនេះ។

ដានី: ក្មេងៗរៀនច្រើន ហីក៏យ៉ាងម៉េច?

ភួន: ច្រើន! វាម៉ាដូរហ្នឹង២០, ៣០ នាក់អីចឹងទៅណា។

ដានី: ចុះលោកគ្រូដែរបង្រៀនគាត់នៅស្រុកភូមិយើងដែរ?

ភួន: បាទ! នៅស្រុកភូមិហ្នឹង។

ដានី: ឈ្មោះអីទៅគ្រូ អ្នកបង្រៀន?

ភួនៈ មានគ្រូដែន សព្វថ្ងៃគាត់នៅ គ្រូកេង គាត់ស្លាប់ហើយ គ្រូឃីម គាត់នៅប៉ោយប៉ែត ណុះសព្វថ្ងៃ ។

ដានីៈ រៀនបានប៉ុន្មានឆ្នាំដែរ?

ភួនៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ បាន៣ឆ្នាំ ។

ដារាៈ ថ្នាក់ទី៣ ឥឡូវនេះ!

ភួនៈ បាទ! ថ្នាក់ទី៣ ឥឡូវ ។

ដានីៈ ដល់ឆ្នាំណាបានឈប់ ថ្នាក់ទី១០ ហ្នុង?

ភួនៈ ខ្ញុំឈប់ឆ្នាំ៧៥ ឆ្នាំ៧៥ បានខ្ញុំទៅរៀនបន្តទៀត ខ្ញុំចូលនៅកុមារអនុភាពវិញណា នៅ៧៦ហ្នឹង ដល់៧៧បានខ្ញុំទៅគិរីវង្ស នៅធ្វើការបណ្តើររៀនបណ្តើរហ្នុង រៀនបានពេលថ្ងៃត្រង់ម៉ោង១១ ដល់ ម៉ោង១២ រៀនបានមួយម៉ោង ពេលព្រឹកធ្វើការ ពេលល្ងាចធ្វើការ ។

ដានីៈ ឆ្នាំ៧៦ទៅនៅគិរីវង្ស?

ភួនៈ បាទ!

ដានីៈ ម៉េចបានឆ្នាំ៧៦ទៅនៅគិរីវង្ស?

ភួនៈ ខ្ញុំទៅកាលហ្នុង អ៊ំទិត គាត់យកទៅ ។

ដានីៈ គាត់យកទៅតែពូមួយ ឬទាំងក្រុមគ្រួសារ?

ភួនៈ តែខ្ញុំមួយ ។

ដានីៈ ចុះឪពុកម្តាយពូ?

ភួនៈ ឪពុកម្តាយខ្ញុំនៅនេះទាំងអស់ ។

ដានីៈ ឆ្នាំ៧៦ហ្នឹងកាលតាទិតគាត់យកពូទៅ...

ភួនៈ កាលហ្នុងតាទិត គាត់នៅធ្វើចៅហ្វាយស្រុកគិរីវង្ស ។

ដានីៈ កាលហ្នុងគាត់ទៅធ្វើចៅហ្វាយស្រុកពីឆ្នាំណាមក?

ភួនៈ ខ្ញុំអត់ដឹងដែរ ដឹងតែពេលគាត់យកខ្ញុំទៅហ្នុង គាត់នៅធ្វើចៅហ្វាយស្រុកនៅហ្នឹង ប្រហែល ជាខ្ទង់ដើមឆ្នាំ៧៦អីហ្នុងតាមមើល ។

ដានីៈ កាលហ្នុងគាត់មានឈ្មោះអីផ្សេងទៀតទេ?

ភួនៈ អត់! ឈ្មោះតែអីចឹងរហូត ។

ដានីៈ គេហៅគាត់ថាម៉េចទៅ?

ភួនៈ គេហៅតែអ៊ំទិតៗរហូត ។

ដានី៖ អត់មានឈ្មោះហៅក្រៅអីផ្សេងទៀតទេ?

ភួន៖ អត់! ទិត រហូតតាំងពីដើមមកហៅតែអ៊ីចឹង មិនដែរដូរទេ។

ដានី៖ កាលពូទៅហ្នឹង ពូទៅនៅផ្ទះជាមួយគាត់ឬក៏យ៉ាងម៉េច?

ភួន៖ ខ្ញុំទៅនៅជាមួយគាត់បានប្រហែលកន្លះខែទេ ក្រោយមកបានគាត់ឲ្យទៅនៅកន្លែងធ្វើអំពូលថ្នាំ ស្លអំពូលថ្នាំ។

ដានី៖ នៅកន្លែងស្លអំពូលថ្នាំ?

ភួន៖ បាទ!

ដានី៖ កាលហ្នឹងពូអាយុប៉ុន្មាន?

ភួន៖ ខ្ញុំកាលហ្នឹងអាយុប្រហែល១៨។

ដានី៖ ដូចថាកន្លែងស្លអំពូលថ្នាំហីផ្ទះគាត់នៅជិតគ្នា ឬក៏យ៉ាងម៉េច?

ភួន៖ នៅឆ្ងាយ! គាត់នៅទន្លាប់ណោះ ខ្ញុំនៅគិរីវង្សណោះ

ដានី៖ អីចុងកាលហ្នឹងកន្លែងមន្ទីរស្រុកគិរីវង្សនៅ ទន្លាប់ទេ?

ភួន៖ បាទ! នៅទន្លាប់ នៅស្វាយព្រៃ ស្វាយសយើងនេះ។

ដានី៖ ពូនៅគិរីវង្ស?

ភួន៖ បាទ!

ដានី៖ ចុះកន្លែងស្លថ្នាំហ្នឹងយ៉ាងទៅលោកពូអាចរៀបរាប់ ដូចថាពូចូលទៅកន្លែងហ្នឹង...

ភួន៖ កន្លែងនោះ អត់មានគ្នាច្រើនទេ មានគ្នាតែ៣នាក់ ធ្វើជាឡធម្មតា ឡហ្នឹងគេដាក់ឆ្នាំងតែ៤ទេ ធ្វើឆ្នាំងអំពីដីហ្នឹង ដាក់ឆ្នាំងគ្រប់៤ជ្រុងហើយបានបូកជិតជាឡហើយបានដាក់ធ្យូងណា ហើយបាន រើអំបែងដបចូលក្នុងឆ្នាំងហ្នឹងទាំងអស់ រើរើធាក់កង់វានោះឲ្យវារលាយល្មមម៉ាផ្លិកើតហើយយក ដែកទីបមូរវា ផ្លិវាឲ្យប៉ោងទៅទាញវាជាដើមវែង មួយដើមៗ១០ម៉ែត្រ ២០ម៉ែត្រទៅណា ហើយបានយកមក កាត់ខ្លីៗវិញ ធ្វើជាអំពូលវិញ។

ដានី៖ យកអំបែងដបហ្នឹងមកស្លធ្វើអំពូលថ្នាំ?

ភួន៖ បាទ!

ដានី៖ អំពូល ប៉ុណ្ណាទៅ?

ភួន៖ អំពូលដូចអំពូលថ្នាំយើងធម្មតាសព្វថ្ងៃ អាស្រួចដើម ស្រួចចុងនោះ កាលហ្នឹងអំពូលយើងពី ដើមមានតែអីចឹងទេ ជំនាន់ប៉ុល ពត នោះ អាទឹកបេដូ បេអង គឺអាទឹកអំពូលស្រួចចុងស្រួច ដើម ចងកៅស៊ូបាច់ៗ ១០ៗ។

ដានី៖ ធ្វើអំពូលហ្នឹងមានគ្នាតែ៣នាក់ទេ?

ភួន៖ បាទ! មានមេជាងមួយ និងកូនជាង២នាក់ប៉ុនៗគ្នាហ្នឹង ២នាក់ប៉ុនៗគ្នា មេជាង ឈ្មោះបង ដួសៗ គាត់អ្នកបច្ចេកទេស។

ដានី៖ មេជាងឈ្មោះ ដួស!

ភួន៖ បាទ!

ដានី៖ ចុះម្នាក់ទៀត?

ភួន៖ ម្នាក់ទៀតឈ្មោះ រឿន។

ដានី៖ ត្រូវជាបងប្អូនពូដែរ?

ភួន៖ អត់ទេ! គេនៅស្រុកហ្នឹងដែរ នៅខាងភ្នំក្រពើ។

ដានី៖ យើងធ្វើអំពូលថ្នាំហ្នឹងឲ្យទៅខាងមន្ទីរពេទ្យឬយ៉ាងម៉េច?

ភួន៖ ឲ្យទៅមន្ទីរពេទ្យស្រុក កាលហ្នុងប្រពន្ធតាទិតហ្នឹង គាត់នៅខាងមន្ទីរពេទ្យស្រុក។

ដានី៖ ប្រពន្ធគាត់ឈ្មោះអី?

ភួន៖ ឈ្មោះ គេន។

ដានី៖ ឈ្មោះអីគេនគាត់?

ភួន៖ ឈ្មោះអីទេ?

ដានី៖ កាលហ្នុងគេហៅគាត់យ៉ាងម៉េច?

ភួន៖ គេហៅយាយគេនៗ គាត់ប្អូនតាម៉ុក ប្អូនពៅតាម៉ុក។

ដានី៖ គាត់ធ្វើប្រធានពេទ្យនៅគិរីវង្ស?

ភួន៖ បាទ! ប្រធាន។

ដានី៖ មន្ទីរពេទ្យគិរីវង្សនៅម្តុំណាទៅ?

ភួន៖ មន្ទីរពេទ្យគិរីវង្សនៅស្រុកគិរីវង្សហ្នុងម៉ង នៅកន្លែងទីរួមស្រុកហ្នុងម៉ង នៅកន្លែងផ្សារស្រុក ផ្សារគិរីវង្សហ្នុង ខ្ញុំទៅឃើញផ្ទះថ្មបាក់បែកអស់ហើយ ខ្ញុំទៅអត់មាននៅទេ។ ៧៧ បានខ្ញុំ ទៅដល់ហ្នុង ពីដើមខ្ញុំនៅវត្តសុបិន្ត ចេញពីវត្តសុបិន្តបានទៅគិរីវង្ស។

ដានី៖ ចុះកាលហ្នុងតាទិត យាយគេន គាត់មានកូនចៅប៉ុន្មាននាក់ដែរ?

ភួន៖ គាត់មានកូនចៅ៣នាក់ ប៉ុន្តស្លាប់មួយនៅសល់តែ២ទេ។

ដានី៖ ឥឡូវសល់តែ២ទេ!

ភួនៈ អត់ទេ! កាលហ្នុង កាលឆ្នាំ៧០ជាង មាន៣នាក់ តែយន្តហោះទម្លាក់ស្លាប់នៅលើនេះមួយ សល់២ ដល់បានធ្វើដំណើរទៅ... សល់៤នាក់ ។

ដានីៈ សព្វថ្ងៃបាន៤នាក់!

ភួនៈ បាទ! ស្លាប់អស់២ ។

ដានីៈ ស្លាប់អស់២!

ភួនៈ បាទ! ៦នាក់ ។

ដានីៈ កូនគាត់៦នាក់ ស្លាប់អស់២!

ភួនៈ បាទ!

ដានីៈ ឈ្មោះអីខ្លះទៅ?

ភួនៈ ឈ្មោះ តាំ នៅប្តីអាឡាពល់ថ្ងៃហ្នឹង អាទេព ស្លាប់យន្តហោះទម្លាក់នៅនេះពីលើនេះ អូស្លាប់ ៣ អាទីមួយទៀត នៅសល់ អាសិទ្ធិ, ថាវរិទ្ធ និង មីពៅ ស្លាប់អាពេជមួយទៀត ស្លាប់អស់៣ ស្រី១ ប្រុស២ ។

ដានីៈ ឥឡូវនៅសល់ ឈ្មោះ តាំ, ថាវរិទ្ធ...

ភួនៈ បាទ! ឈ្មោះតាំ ថាវរិទ្ធ, សិទ្ធិ និង ពៅ ។

ដានីៈ ចុះពូកាលនៅគិរីវង្សហ្នុង ដូចថាមន្ទីរស្រុកនៅទម្លាប់នេះ ហីមន្ទីពេទ្យនៅខាងទីរួមស្រុកគិរីវង្ស?

ភួនៈ បាទ!

ដានីៈ ចុះកាលហ្នុងតាទិត យាយកេន គាត់នៅជាមួយគ្នា ឬក៏អត់ទេ?

ភួនៈ អត់ទេ! នៅបែកគ្នា ។

ដានីៈ ប៉ុន្តែក្រោយពីធ្វើការអីគាត់មកនៅជួបជុំគ្នាដែរ?

ភួនៈ ប្រហែលជាមួយខែ ឬកន្លះខែអីបានមកនៅជួបជុំគ្នាម្តង...

ដានីៈ តាទិតកាលហ្នុងកាត់មានឈ្មោះអីផ្សេង ដូចថាឈ្មោះជាលេខជាអី?

ភួនៈ លេខមាន ប៉ុន្តែខ្ញុំភ្លេចលេខ ជំនាន់នោះប្រើអីចឹងដែរ ភ្លេចហើយដូចថាយើងអត់សូវចងចាំ ណា ។

ដានីៈ ពូនៅកន្លែងស្នងថ្នាំហ្នឹងអត់មានទៅណា?

ភួនៈ បាទ! នៅតែកន្លែងស្នងថ្នាំហ្នឹង គេឲ្យទៅលើកភ្លឺ លើកសំណាប ពេលថ្ងៃការងារផ្ទាល់ខ្លួន ពេលយប់ការងាររួមលើកភ្លឺស្រែ ។

ដានីៈ ហូបចុកម៉េចដែរកាលហ្នុង?

ភួនៈ ហូបចុក បបរដែរ ប៉ុនបបរដាប់វែកណា ។

ដានីៈ យើងហូបម៉ាន្អែត?

ភួនៈ បាទ! ម៉ាន្អែត គេអត់កំណត់ទេ ប៉ុនបបរដាប់វែក ។

ដានីៈ ចុះម្ហូប?

ភួនៈ ម្ហូបទូទៅចំរុះ អត់ទៀងទេ ជួនកាលម្ជូរព្រលិត ជួនកាលម្ជូរត្រកួនអីចឹងទៅ ។

ដានីៈ ចុះដូចពូមានអីគាត់ធ្វើជាគណៈស្រុកអីចឹង យើងចង់មកលេងឪពុកម្ដាយអី...

ភួនៈ អត់! ខ្ញុំអត់ដែរបានមក ខ្ញុំទៅ ទៅរហូត ជួបគាត់ឆ្នាំ៨៥ ។

ដានីៈ ចុះតាទិតកាត់គណៈស្រុក ដូចថាក្នុងជួរគណៈស្រុកទៀតដែលបន្ទាប់ៗគាត់មានឈ្មោះអីខ្លះទៅ?

ភួនៈ មានពីរនាក់ទៀតបន្ទាប់ៗគាត់ ប្រុសមួយ ស្រីមួយ ។ ស្រី ខ្ញុំភ្លេចឈ្មោះគាត់បាត់ហើយ ។

ដានីៈ ប្រុសឈ្មោះអីគេ?

ភួនៈ ឈ្មោះតាប៉ុម ខ្ញុំភ្លេចទៅមិនដឹងឈ្មោះ ប៉ុម ឬតុំ ទេ ។

ដានីៈ គាត់នៅស្រុកណាទៅ?

ភួនៈ ខ្ញុំអត់ស្គាល់ស្រុកទេ ប៉ុន្តែខ្ញុំធ្លាប់ដឹងថា អីចេះបានខ្ញុំដឹងនោះ វាទំនាស់គ្នារឿងបាយ រឿងបបរហ្នឹង ។ តា ប៉ុម គាត់ឲ្យបបរ ហើយាយហ្នឹងគាត់ឲ្យបាយ ដល់វាអត់ត្រូវគ្នា គាត់ឲ្យក្រសួងមន្ទីរហ្នឹងហូបបាយ ដល់តានោះអត់ទេ ថាឲ្យហូបបបរ ទំនាស់ហ្នឹងខ្ញុំចាំតែកន្លែងហ្នឹង ពីព្រោះយើង ម្នាក់ៗ ចង់ហូបបាយកាលពីជំនាន់ហ្នឹងណា ដល់រឿងបាយរឿងបបរហ្នឹងចងចាំរហូត ។

ដានីៈ អីចឹងតាទិត គាត់កាត់អីឲ្យយ៉ាងម៉េចទៅ?

ភួនៈ អត់ដឹងថាគាត់កាត់អីយ៉ាងម៉េចទេ ស្រាប់តែចេញជាបបរឈ្នាល បបរប៉ិហ្នឹងមក ពីដើមបបរ រាវ មួយគេខ្លះគេដាក់៥ឬ១០កំប៉ុងអីចឹង ដល់ក្រោយមកខាប់ យើងដូចមកដាប់វែករលាក់វែក តវ៉ាគ្នា ចាំតែកន្លែងហ្នឹងមួយទេដែរចាំ ។

ដានីៈ ពូនៅកន្លែងស្ទួង្ស៊ារហូតដល់បែកឆ្នាំ៧៩?

ភួនៈ អត់ទេ! ខ្ញុំនៅបាន ចុង៧៧ ខ្ញុំឡើងទៅរៀនពេទ្យនៅភ្នំពេញ ខ្ញុំនៅបានប្រហែលជាមួយឆ្នាំទេ ខ្ញុំមករៀនពេទ្យនៅភ្នំពេញ ។

ដារ៉ាៈ ពូមករៀនពេទ្យនៅភ្នំពេញរៀននៅពេទ្យរុស្សីឬ?

ភួនៈ បាទ!

ដារ៉ាៈ អីចឹងពូរៀនមានជាមួយ ពូនឿន?

ភួនៈ ខ្ញុំរៀនវគ្គក្រោយ នឿន រៀនវគ្គមុន ។

ដារ៉ាៈ អ៊ីចឹងពូនឿនរៀន វគ្គមុនពូ?

ភួនៈ បាទ! គាត់ចូលមធ្យម ខ្ញុំបឋម ។

ដារ៉ាៈ ចុះកាលពូរៀននៅពេទ្យរុស្ស៊ីហ្នឹងមានការប្រជុំ មានអីទេពូ?

ភួនៈ មានដែរ! ប្រជុំជាក្រុមជាអីហ្នឹង ។

ដារ៉ាៈ ហើមានថ្នាក់ធំ ថ្នាក់តូចអីគេមកចូលរួមទេ មានវគ្គនយោបាយអីទេពូ?

ភួនៈ អត់ទេ! អានេះប្រជុំតែរឿងការងាររៀន ប្រជុំជាក្រុមៗ ពិភាក្សាគ្នា ប្រជុំផ្នែកនយោដូចអត់មានទេ ។

ដារ៉ាៈ ប្រជុំផ្នែកនយោបាយអត់មានទេ?

ភួនៈ បាទ! អត់ ។

ដារ៉ាៈ ចុះមានពេទ្យណាមួយចុះមកប្រជុំណែនាំ

ភួនៈ ប្រធានពេទ្យ គាជួន ជឿន ចុះមកបង្រៀននៅហ្នឹង គាត់មកបង្រៀនជាក់ស្តែង ២ ទៅ៣ដងដែរ ។

ដារ៉ាៈ ចុះអៀង ធីរិទ្ធិ!

ភួនៈ អត់! អត់ដែរឃើញទេ ។

ដារ៉ាៈ តែវគ្គពូនឿន ពូនឿន គាត់ថាមាន អៀង ធីរិទ្ធិ ចូលរួម!

ភួនៈ គាត់ចូលមធ្យមហើយវា ថ្នាក់គេធំៗចូលរួម ដល់ត្រឹមបឋមវាអត់ទេ អត់ទាន់ទេ ។

ដារ៉ាៈ ពូរៀនវគ្គបឋមហ្នឹងបានប៉ុន្មានខែដែរ ពូរៀនហ្នឹង?

ភួនៈ ខ្ញុំរៀនកាលហ្នឹងបានប៉ុន្មានទេ បាន៦ខែដែរ ត្រូវចេញមកជាក់ស្តែងរយៈពេលមួយឆ្នាំ បានឡើងចូលវគ្គមធ្យមវិញ ចេញមកជាក់ស្តែង ទទួលយួនវ៉ៃព្រំដែនយើងចូលដល់គិរីវង្ស ជាក់ស្តែងនៅ តានីហ្នឹង ពេទ្យស្រុកតានី ពេទ្យហ្នុងមានតែ២នាក់ទេ មកពីរៀនមកមានតែ២នាក់ទេ បគ្គលិក អ្នកជម្ងឺរាប់រយ ។

ដានីៈ ពូរៀនផ្នែកអីកាលហ្នុង?

ភួនៈ ទូទៅ!

ដានីៈ ជម្ងឺទូទៅ?

ភួនៈ ជម្ងឺទូទៅ ។

ដារ៉ាៈ ជាក់ស្តែង ពូឃើញអ្នកជម្ងឺនៅតានី ជាយុទ្ធជន ឬក៏ជាប្រជាជនធម្មតា?

ភួនៈ ជាប្រជាជន ។

ដារ៉ាៈ កាលហ្នុងឈឺស្លាប់អីដោយសារជម្ងឺអីភាគច្រើន?

ភួនៈ ខ្វះជីវជាតិកាលហ្នុង ភាគច្រើនហើម ។

ដារ៉ាៈ ភាគច្រើនហើម!

ភួនៈ បាទ! ជំនាន់ហ្នុង ខ្ញុំថ្ងៃថ្មើរនេះមិនទាន់បានចូលកន្លែងផង ដើរដឹកថ្នាំ ឬសឈើយកមកត្រាំទឹក បុគ្គលិកតែ២ ស្លាប់អីបានគេជួយសែងដល់ទូក ចែវទូកទៅតាមទំនប់យកទៅកប់នៅចុងទំនប់នៅខាងណុះ ។

ដារ៉ាៈ កប់នៅខាងណា?

ភួនៈ អាចុងទំនប់យើងឯពេទ្យតានី អាហ្នឹងសាលារៀនទេ ពីដើមក៏សាលារៀន ឥឡូវក៏សាលារៀនដែរ កន្លែងហ្នឹង អាចុងជើងភ្នំ...

ដារ៉ាៈ ភាគច្រើនរឿងហើមហ្នឹង?

ភួនៈ បាទ! ជម្ងឺភាគច្រើនជម្ងឺហើម ។

ដារ៉ាៈ អត់មានដាទ័ពត្រូវរបួសស្នាមអីទេ?

ភួនៈ អត់! ទ័ពវានៅផ្នែកជិតគ្នាដែរ ប៉ុនខ្ញុំនៅខាងទូទៅ វានៅជិតគ្នាដែរ គេនៅផ្នែកខាងរបួសហ្នុងនៅជិតគ្នាដែរប្រហែលពីនេះទៅផ្ទះ ពេទ្យនឿន កាលហ្នឹងខ្ញុំនៅផ្នែកខាងទូទៅ ទៅពីខាងពេទ្យទៅគេឲ្យខ្ញុំ ដាក់ស្ពែងខាងរបួសទេ ដល់ពេលគេអ្នកនោះ ពេទ្យចាស់គេរុញទៅខាងហ្នឹងអស់ទៅខ្ញុំចូលទៅ គេឲ្យចូលខាងទូទៅហ្នឹងម៉ង

ដារ៉ាៈ កាលហ្នុងជម្ងឺហើម ពូច្រើនដាក់ថ្នាំអី?

ភួនៈ ភាគច្រើនគេឲ្យចាក់ពួកគេកំភ្លិច ពួកបេខូ អីហ្នឹង ពួកវីតាមីនហ្នឹងណា រួចយើងផ្សំឬសឈើដាំទឹកឲ្យគាត់ហូបបន្ទាប់បន្សំទៅ ។

ដារ៉ាៈ មានជាទេ!

ភួនៈ បើតិចជា បើខ្លាំងយូអត់ជាទេមានតែស្លាប់ ជម្ងឺនោះបើយើងឥឡូវគេហៅថ្លើមគ្រិនណាទាចទឹកណា ខ្ញុំជួបភាគច្រើនអ្នក អីចឹងបានថាអ្នកជម្ងឺហ្នឹងសព្វថ្ងៃនេះ ខ្ញុំស៊ើបសួរពីព្រោះខ្ញុំព្យាបាល ឥឡូវហ្នឹងក៏អស់ច្រើនដែរ ពីមុនក៏អស់ច្រើន អ្នកដែរបូមគឺស្លាប់ ។

ដារ៉ាៈ បូមម៉េច?

ភួនៈ បូមទឹកពីហ្នុងពោះ បើអត់បូមប្រហែលមានសង្ឃឹមបានរស់ ។

ដានីៈ បើបូមដឹងតែស្លាប់ហើយ?

ភួនៈ ដឹងតែស្លាប់ហើយ ដល់បូមយូទៅគឹងទៅ មិនមែនបូមហើយស្រក់ទេណា បូមថ្ងៃហ្នឹងមួយលីត្រ ស្អែកត្រូវបូមចេញពីលីត្រ បើខាងស្អែកត្រូវបូមចេញ៤លីត្រ ឡើងទល់តែមនុស្សហ្នុងស្លាប់ បើអត់ បូមដូចថានៅចំណុះហ្នុងនៅតែ២លីត្រ គឺនៅតែ២លីត្រហ្នឹង យើងបញ្ចុះជាថ្នាំជាអី វាអត់ឡើងខ្លាំងទេ ។

ដានីៈ ចុះមន្ទីរពេទ្យហ្នឹងមានគ្នាតែ២នាក់អីចឹង នៅតានីហ្នឹង?

ភួនៈ វាពីដើម វាមានគ្នាច្រើនមែននៅកន្លែងហ្នឹង ប៉ុន្តែពេលខ្ញុំទៅដល់គេរុញបុគ្គលិកចាស់ទៅកន្លែងទ័ពកាលហ្នឹងវារបួសធ្ងន់ច្រើន ។

ដានីៈ អូ! មានផ្នែកគេ?

ភួនៈ បាទ!

ដាវ៉ាៈ របួសកាលហ្នុង របួសមកពីខាងណា?

ភួនៈ គិរីវង្ស យួនវៃចូលមាំស្រុកគិរីវង្សមិនអស់កាលហ្នុងចុងឆ្នាំ៧៧ ពាក់កណ្តាល៧៨ យកស្រុកគិរីវង្សបានទាំងអស់ ។

ដានីៈ ស្រុកអីផ្លាស់មកម៉េចទៅ?

ភួនៈ មិនដឹង! ខ្ញុំ ឮគេថាចូលដល់មកខាងណេះស្រុកគិរីវង្ស វាចូលចង់អស់ព្រោះគិរីវង្ស តែចូលមកជិតខាងតានីហើយ ចង់ហើយមាំស្រុកហ្នុង ចូលដល់ឃុំស្តីត្រង់ណា ចាអូ ។

ដានីៈ ដល់ពេលខាងយួនវៃចូលមកអីចឹង ដូចតាទិតអីគាត់អត់មានបញ្ហាអីដែរ?

ភួនៈ កាលហ្នុង គាត់ទៅនៅនោះបាត់ហើយ គាត់ទៅនោខាងបាត់ដំបងហើយ កាលយួនវៃចូលហ្នុង ។

ដានីៈ គេផ្លាស់គាត់ទៅឬ?

ភួនៈ បាទ! ដូរគាត់ទៅបាត់ហើយ ។

ដានីៈ ផ្លាស់ទៅឆ្នាំណា?

ភួនៈ ....ដំបូងគាត់ដូរពីស្រុកមកខេត្ត មកតាកែវ ចេញពីតាកែវគាត់មកនៅក្រចេះ បានទៅពីក្រចេះទៅ គាត់ទៅនៅខាងបាត់ដំបង ។

ដានីៈ គាត់ផ្លាស់ពីគិរីវង្សមកតាកែវ គាត់នៅធ្វើអីទៅនៅតាកែវ?

ភួនៈ នៅគណៈតំបន់ ។

ដានីៈ គណៈតំបន់ប៉ុន្មានហ្នឹង?

ភួនៈ គណៈតំបន់ ១៣ ។

ដានី៖ ពូមានចាំឆ្នាំខែទេ?

ភួន៖ ឆ្នាំហ្នឹង ប្រហែលជាដើមឆ្នាំ៧៨ ព្រោះកាលហ្នឹងគាត់ដូរមកនៅហ្នឹង ខ្ញុំត្រូវទៅរៀននៅភ្នំពេញ គាត់ដូរមកនៅខេត្តហ្នឹង គាត់យកខ្ញុំពីគិរីវង្សមក ឲ្យខ្ញុំទៅរៀននៅនោះម៉ង ។

ដានី៖ អ៊ីចឹងគាត់មកនៅគណៈតំបន់១៣ហ្នឹងនៅដើមឆ្នាំ៧៨!

ភួន៖ បាទ!

ដានី៖ បានរយៈពេលប៉ុន្មានបានគាត់ទៅក្រចេះទៀត?

ភួន៖ ប្រហែលជា៦ខែតាមមើល ខ្ញុំអត់ចាំច្បាស់កាលហ្នឹង ដឹងតាមពួកម៉ាកមួយ ខ្ញុំមករៀនហ្នឹង មកដល់គាត់យកពួកម៉ាកខ្ញុំទៅជាមួយគាត់ម៉ង នៅរៀនតែខ្ញុំ ។

ដារ៉ា៖ ចុះគ្រួសារគាត់ ពេលដែលគាត់ផ្លាស់ទៅ?

ភួន៖ គ្រួសារគាត់ប្រហែលជាអត់ ទៅតែគាត់ គ្រួសារគាត់នៅនេះ

ដារ៉ា៖ គ្រួសារគាត់នៅជាពេទ្យ...

ភួន៖ គ្រួសារគាត់ ប្រហែលជាមកនៅតាកែវតាមមើល ខ្ញុំអត់ដឹងទេកាលហ្នុងខ្ញុំលែងសួរចាំលែង សួរយកចិត្តទុកដាក់គិតអីចឹង១ទៅ ប៉ុន្តែខ្ញុំធ្លាប់ឃើញគាត់នៅតាកែវក្រោយមក ។

ដានី៖ យាយកេន?

ភួន៖ បាទ!

ដានី៖ គាត់ឈប់ទៅនៅគិរីវង្សទៀតហើយ?

ភួន៖ បាទ! វាផ្លាស់ផ្តូរ ដោះដូរលឿនណាស់កាលហ្នុង ។

ដានី៖ ដល់ពេលគាត់នៅតំបន់១៣ហ្នឹងបាន៦ខែគាត់ផ្លាស់ទៅប្រចេះ?

ភួន៖ បាទ!

ដានី៖ នៅក្រចេះហ្នុងគាត់ធ្វើអីទៅ?

ភួន៖ ខ្ញុំអត់ដឹង! ដល់ពេលគាត់ទៅដល់បាត់ដំបង បានខ្ញុំទៅពីហ្នឹងទៅទៀត ទៅជួបគាត់នៅបាត់ដំបង ទៀត ។

ដានី៖ ទៅបាត់ដំបងគាត់នៅឯណា?

ភួន៖ នៅអំពិលប្រហោង ។

ដានី៖ អំពិលប្រហោង!

ភួន៖ បាទ!

ដារ៉ា៖ ភូមិអី ភូមិអំពិលប្រហោង!

ភួនៈ ខេត្តបាត់ដំបង អាហ្នុងភូមិអី អំពិលប្រហោងហ្នុង អាយើងចេញពីនេះទៅភ្នំសំពៅណា ជិតតាកោទាប ម្តុំតាកោទាប ។

ដានីៈ បាននន់!

ភួនៈ កាលហ្នុងដឹងស្រុកបាននន់ ឬស្រុកអី ផ្លូវជាតិលេខ១០ហ្នឹងដែរ ជាប់ក្រុងហ្នឹងដែរ ។

ដានីៈ ភ្នំសំពៅ!

ដារាៈ មោង!

ភួនៈ អត់ទេ! ផ្លូវយើងចេញទៅបាត់ដំបង ភ្នំសំពៅ ហួសផ្លូវរទេះភ្លើងបន្តិចមិនដល់អំពិលប្រហោងហ្នុងវានៅជាយក្រុងទេ ។

ដានីៈ គាត់នៅបាត់ដំបងហ្នុងគាត់ទៅទទួលខាងអីគេ?

ភួនៈ កាលហ្នុងអត់ដឹងការងាររគាត់ ពីព្រោះខ្ញុំទៅដល់ហ្នុងខ្ញុំចូលខាងរោងម៉ាស៊ីនក្រឡឹងវិញ ជាងក្រឡឹងវិញ ខ្ញុំដូរជំនាញទៀតហើយដល់ហ្នឹង ។

ដានីៈ គាត់នៅបាត់ដំបងបានរយៈពេលប៉ុន្មាន?

ភួនៈ នៅរហូតដល់យួនចូល ។

ដានីៈ បានប៉ុន្មានខែទៅ?

ភួនៈ ខ្ញុំអត់ចាំ ។

ដានីៈ កាលគាត់នៅហ្នុងនៅក្នុងគណៈភូមិភាគពាយ័ព្យ?

ភួនៈ ប្រហែលជាភូមិភាគ តាមមើល...ភូមិភាគពាយ័ព្យ ប៉ុនខ្ញុំអត់ដឹងណា គ្រាន់ខ្ញុំទៅដល់ខ្ញុំចូលទៅផ្នែកការងារខ្ញុំទៅ នៅខាងជាងក្រឡឹង ។

ដានីៈ ពូផ្លាស់ជំនាញពីពេទ្យទៅធ្វើជាងក្រឡឹងវិញ?

ភួនៈ បាទ! ធ្វើជាងក្រឡឹងវិញ ។

ដានីៈ ម៉េចអីចឹងបានចេញពីរៀនពេទ្យហើយទៅធ្វើជាងក្រឡឹងវិញ?

ភួនៈ ទេ! វាដូចថាយើងអត់មានចំណូលទៅខាងអីស្រេចតែគេឲ្យទៅធ្វើខាងអីធ្វើខាងហ្នុងម៉ង...

ដានីៈ តាទិតគាត់ធ្វើឬ?

ភួនៈ ទេ! មិនដឹងពីណាគេឲ្យធ្វើទេ ស្រាប់គេថាមិត្តឯងទៅនៅខាងនេះៗអីចឹងទៅ ។

ដានីៈ នៅជិតគាត់ដែរ?

ភួនៈ គាត់នៅអំពិលប្រហោង ខ្ញុំនៅអន្លុងវិញណោះ មានក្រុងម្នាក់ ។

ដានីៈ គាត់មកធ្វើការនៅមន្ទីរភូមិភាគ?

ភួនៈ គាត់មិនដឹងម៉េចដែរ បែបមកខាងភូមិភាគហើយ ខ្ញុំអត់សូវដែលបានចូលក្រុងទេនៅអន្លុងវិញអត់ សូវបានចូលក្រុងបាត់ដំបងអត់ដែរផង នៅហ្នឹងរហូតដល់ពេលយួនចូលមក យប់ហ្នឹងបានឃើញគាត់អោយគេយកឡានមកដឹកខ្ញុំទៅប៉ៃលិនៗ ទៅទាំងយប់ ។

ដានីៈ ជិះឡានទៅជាមួយគាត់ដែរ?

ភួនៈ បាទ!

ដានីៈ អីចឹងពេលហ្នឹង ពូជិះឡានយ៉ាងម៉េច ពេលដែលយួនចូលមកទៅប៉ៃលិនហ្នឹង ដូចថាកាលហ្នឹងឡានម៉ាក់អីហើយ ទៅគ្នាប៉ុន្មាននាក់ដែរ?

ភួនៈ ឡានជិះដំបូង ពួកអាឡងរូវ៉ៃ ជូនប្រពន្ធគាត់ទៅទុកនៅប៉ៃលិន ។

ដានីៈ ជិះគ្នាប៉ុន្មាននាក់ ក្នុងឡានហ្នឹង?

ភួនៈ ក្នុងឡាន មានគាត់ហីកូនចៅ ហីពួកខ្ញុំប្រុសៗ៣នាក់ ម៉ាឡាន៦,៧នាក់ដែរណា ។

ដានីៈ ៦,៧ នាក់ទាំងប្រពន្ធ ទាំងកូនគាត់?

ភួនៈ បាទ!

ដានីៈ ថ្ងៃណាដែរយើងចេញពីបាត់ដំបងទៅ!

ភួនៈ សួរថ្ងៃចប់ហើយ!

ដានីៈ ពីព្រោះថាថ្ងៃ៧មករា យួនចូលមកដល់ទីក្រុងភ្នំពេញ បានន័យថាទម្រាំតែយួនទៅដល់បាត់ដំបងប្រហែលថ្ងៃណាបានគាត់ចេញពីបាត់ដំបង!

ភួនៈ ខ្ញុំចាំបានថា ពេលខ្ញុំទៅដល់ប៉ៃលិន គេដុតឃ្លាំងគ្រាប់នៅបាត់ដំបង ។

ដានីៈ ទៅមុនយួនចូលដល់ឬ?

ភួនៈ ទៅមុនដល់! ទៅដល់ហើយខ្ញុំត្រឡប់មកនៅម្តុំស្ពោ ម្តុំស្ទឹងវិញ បាទ!យកគាត់ទៅទុកហ្នឹងហើយខ្ញុំត្រឡប់មកក្រោយវិញ បានខ្ញុំចាប់ផ្តើមកាន់អាវុធពីពេលហ្នឹងទៅ ជាទូរទៅមិនថាកម្មករមិនថាអីទេ កាន់អាវុធទាំងអស់គ្នា ។

ដារ៉ាៈ កាន់អាវុធដើម្បីទប់ទល់ជាមួយវៀតណាម?

ភួនៈ បាទ! យើងការពារ យើងទប់ទល់ ។

ដានីៈ កាលក្នុងពេលពូត្រឡប់មកវិញពូមកម្នាក់ឯងទេ?

ភួនៈ ជិះឡានមកវិញ យកគាត់ទៅទុកនៅហ្នឹង ។

ដារ៉ាៈ តាទិត តាអីតាឡប់មកវិញដែរ?

ភូនៈ	តាទិត គាត់អត់មានទៅទេ យកតែប្រពន្ធទៅទេ កាលខ្ញុំទៅគាត់នៅបាត់ដំបងអាឡើយទេ គាត់ចេញឡានក្រោយមកទៀត គាត់មានឡានអាហ្វ៊ីប២ទៀតណា ។

ដានីៈ	ប្រពន្ធកូនគាត់ទៅប៉ៃលិន?

ភូនៈ	បាទ!

ដានីៈ	អីចឹងដល់ពេលយួនចូលមកគាត់ទៅប៉ៃលិនដែរឬយ៉ាងម៉េច?

ភូនៈ	អត់ទៅទេ! គាត់នៅម៉ាជួរស្ពោ ម៉ាជួរស្ទឹង ម៉ាជួរត្រែង គាត់នៅម្តុំហ្នឹងទេ ។

ដានីៈ	ពូមកវិញ?

ភូនៈ	បាទ! ខ្ញុំមកវិញ! មកនៅជាមួយគាត់វិញ ។

ដានីៈ	ពេលហ្នឹងយើងរៀបចំកម្លាំងកងទ័ពទៅ ដូចកម្លាំងកងទ័ពហ្នុងទៅយ៉ាងម៉េចទៅដូចថា ជាក្រុម ជាកង ជា...

ភូនៈ	កម្លាំងកាលហ្នុងអត់មានថាទៅពីណា ពីណី យើងថាចំណុះទ័ពតែម្តង ចំរុះជាមួយទ័ពចាស់ បើនិយាយទៅ ទ័ពចាស់ពីរក្មេងមួយ ក្មេងថ្មីតែម្តង ដូចខ្ញុំអីហ្នឹងណា នៅក្នុងម៉ារណ្ឌត្រង់សេ គឺដាក់ទ័ព ចាស់២ ក្មេងមួយៗ គ្រប់អីចឹងទៅ កាលហ្នុងរាយនៅម៉ាជួភ្នំក្រពើ ភ្នំសំពៅ ខ្សែត្រៀមនៅហ្នឹង ហីគាត់នៅស្ទឹងឯណោះ ។

ដានីៈ	គាត់ធ្វើជាអីកាលហ្នុងគាត់?

ភូនៈ	គាត់មិនធ្វើជាអីវិញហើយ មិនដឹងទេ តំណែងការងារខ្ញុំលែងដឹងអស់ហើយ ព្រោះវាដាច់ៗទៅ ច្របូកច្របល់អស់ហើយ ។

ដានីៈ	ពូធ្វើទាហាន ធ្វើជានិរសាគាត់ ឬធ្វើជា...?

ភូនៈ	ជាទ័ពម៉ង! ទ័ពចំរុះជាមួយទ័ពចាស់ម៉ង ។

ដានីៈ	ហើយយ៉ាងម៉េចទៀតទៅ?

ភូនៈ	ពេលយួនវាវ៉ៃបុកពីបាត់ដំបងទៅ វាបាក់ បានខ្ញុំរត់មកជួបគាត់ដងហ្គែត នៅបឹបដេនេះ ។

ដានីៈ	នៅភ្នំបឹបដេ!

ភូនៈ	បាទ! បានខ្ញុំឈប់ធ្វើទ័ព មកនៅជាមួយគាត់ ។

ដានីៈ	ទៅនៅជាមួយគាត់នៅឯណាទៅ?

ភូនៈ	នៅជាមួយគាត់នៅដងហ្គែតហ្នឹង បានឡើងទៅនៅវ៉ៃដែក ។

ដានីៈ	វ៉ៃដែក!

ភូនៈ	វ៉ៃដែក ដងទង់នោះ!

ដានី៖ បាទ!

ភួន៖ ដល់ចេញពីហ្នឹងទៅបានទៅសំឡូត តាសាញ ក្រញូង កាលហ្នុងប្រុងមកណោះវិញ ដែនការគេ កាលហ្នុងគេឲ្យអ្នកខេត្តបាត់ដំបង គេហៅនិរតីណា តាម៉ុក បញ្ជាឲ្យមកណោះវិញទាំងអស់ ។

ដានី៖ មកឯណា?

ភួន៖ មកស្រុកហ្នឹង មកនិរតីវិញ កន្ទុយនៅសំឡូតក្បាលនៅអីនេះនៅពោធិ៍សាតនេះ លាដ បាន យន្តហោះទម្លាក់នៅលាដហ្នុងស្លាប់ច្រើនពេកបានដាច់បកក្រោយវិញអស់ យន្តហោះទម្លាក់ បានគេថា ទៅលែងរួចហើយ យន្តហោះទម្លាក់ងាប់ច្រើនណាស់បានឡប់ទៅក្រោយវិញ បានចូលព្រៃបណ្ដោយ ។

ដានី៖ ចូលព្រៃនៅឯណាទៅ?

ភួន៖ ចូលព្រៃស្រុកសំឡូត ។

ដានី៖ អាហ្នឹងឆ្នាំណា?

ភួន៖ ចូលព្រៃ ឆ្នាំ៧៩ ប្រូតហើយ...

ដានី៖ ចូលព្រៃចាប់ផ្ដើមតស៊ូហ្នឹង...

ភួន៖ អាហ្នឹងទុកឡានចោលព្រៃហើយ ចោលឡាន ចោលអីអស់ហើយ ។

ដានី៖ អាហ្នឹងរៀបចំជាកងទ័ព កងពល ជាកងវរៈអីហើយ?

ភួន៖ មិនទាន់រៀបចំទេ នៅដាច់ដោចអាឡើយទេ នៅរកក្លួចហូបអាឡើយទេ បានឡើងមកនៅជួភ្នំ ព្រំដែនរកក្លួចរកអីមកហូបខ្លួនឯង ពេលនោះ ចុះពីហ្នឹងទៅ ទៅនៅផ្លោងកំពង់កណ្ដាល កំពង់អី វិញ ពេលហ្នឹងឡើងមកនៅព្រំដែនថៃ ចាប់ផ្ដើមបានអង្ករ បានអីហូបហើយ ហ្នុងបានចេញជា កង រៀបចំជាកងវិញហើយ ។

ដានី៖ រៀបចំជាកងយ៉ាងម៉េចទៅកាលហ្នុង?

ភួន៖ ខ្ញុំគេឲ្យនៅខាងទទួលអង្ករពី គេបែកអង្ករមកយើងសម្រាប់ទទួលគិតណា ផ្នែកអង្ករផ្នែកកង ហ្នុង ។

ដានី៖ កាលរៀបកង រៀបអីហ្នឹង គេហៅអី ពូមានតួនាទីអីគេដែរ?

ភួន៖ ខ្ញុំអត់ទេ! មានគ្នាខ្ញុំ២នាក់ គេឲ្យទៅចាំទទួលពេលអង្ករទៅដល់ តាជនគាត់អ្នកទទួលរួមកាលហ្នុង

ដានី៖ តាជន!

ភូនៈ	បាទ! គាត់ប្រមូលមាស ប្រមូលអីតាមកងតាមប្រជាជនអីហើយ គាត់យកទៅដូរជាអង្ករយកមកចែកតាមកង តាមផ្នែកៗអីចឹងទៅ ហីខ្ញុំទទួល ២នាក់ពួកមាក់ខ្ញុំហ្នឹង ចាំទទួលអង្ករហ្នឹងសម្រាប់ផ្គត់ផ្គង់កន្លែងគាត់ ។

ដានី:	ចុះតាទិត?

ភូនៈ	តាទិតគាត់នៅលើព្រំដែន នៅក្នុងដីថៃ ។

ដានី:	គាត់មានតួនាទី ដល់រៀបជាកងទ័ពទៅគាត់មានតួនាទីជាស្អីទៅ?

ភូនៈ	កាលហ្នឹង!

ដានី:	បាទ!

ភូនៈ	កាលហ្នឹងគាត់មិនដឹងនៅផ្នែកខាងស្អីទេ ដូចផ្នែកខាងសេដ្ឋកិច្ចតាមមើល ព្រោះគាត់ផ្គត់ផ្គង់តាជនគាត់ទទួលពីគាត់ដែរណា ព្រោះគាត់អត់ចុះដាប់ គាត់គ្រាន់បញ្ជាមកថាឲ្យទិញចែកឲ្យកងណាៗ ក្រុមណាៗអីចឹងទៅណា ។

ដានី:	ហ្នឹងចាប់ពីឆ្នាំណាទៅ?

ភូនៈ	ហ្នឹងចាប់ពីដើមឆ្នាំ៨០ ។

ដានី:	កាលហ្នុងនៅសំឡូតមានប៉ុន្មានកងពល?

ភូនៈ	នៅសំឡូតមាន៣កងពល ។

ដានី:	កងពលពីណាខ្លះកាលហ្នុង?

ភូនៈ	កងពលតូច មានកងពលតាផាតមួយ តាណើម មួយ តាផល មួយ ។ ផាត ១១០ តាណើម ១០៦ តាផល ហ្នុងមើល មាន៣កងពល ។

ដានី:	ចុះដល់ពេលកងពលធំ ក្តាប់រួម?

ភូនៈ	ក្តាប់រួមតា ម៉េត ។

ដានី:	តា ស៊ូ ម៉េត?

ភូនៈ	បាទ!

ដានី:	តា ម៉េត គាត់ក្តាប់រួម ចុះសមាសជិកគណៈកងពលមានពីណាខ្លះ?

ភូនៈ	ខ្ញុំអត់សូវដឹងផង ។

ដានី:	តាទិត គាត់នៅក្នុងគណៈកងពលហ្នុងដែរ?

ភូនៈ	គាត់នៅទទួលរបៀបមួយមុខសញ្ញាៗ មុខសញ្ញាគាត់ខាង៦៩ហ្នឹង តាម៉េតទៅខាង៧០អីចឹងទៅ តែវានៅក្រោមរបស់តាម៉េតទាំងអស់អីចឹងណា ។

ដានី៖ ចុះកាលហ្នឹងនៅសំឡូតមានសុទ្ធតែកងទ័ព ឬមានប្រជាជនដែរ?

ភួន៖ មានប្រជាជន! តែប្រជាជននៅក្នុងដីថៃ ។

ដានី៖ តែអ្នកគ្រប់គ្រងប្រជាជនពីណាគេ?

ភួន៖ គ្រប់គ្រងប្រជាជនខ្ញុំដូចភ្លេចឈ្មោះអស់ហើយ វាយូពេកទៅភ្លេចអស់វាច្របូកច្របល់ មេច្រើនពេកមិនដឹងពីណាពីណី ។

ដានី៖ ពូឈប់កងទ័ពហើយពេលហ្នឹង?

ភួន៖ បាទ! ខ្ញុំនៅធ្វើដែរ នៅធ្វើទៅជាពេទ្យវិញហើយ ធ្វើទ័ពទៀតចូលទៅទៀតហើយ មុនដំបូងខ្ញុំទទួលចាំ ឃ្លាំងនៅចាំអី បានមួយរយៈពេលខ្ញុំចូលពេទ្យវិញ ពេទ្យទ័ពវិញរហូតមក ។

ដានី៖ ដល់ឆ្នាំប៉ុន្មានដែលយួនវៃបុកចូលយកសំឡូតអីបាន?

ភួន៖ បុកចូលយកបានប្រហែលជា៨៥ ព្រោះខ្ញុំចុង៨៤ខ្ញុំទៅនៅដងរែកហើយ ដូរទៅ ផ្លាស់ទៅនៅដងរែក គាត់មេកងពលតាផាតគាត់ទៅនៅហ្នឹង ក្រោយមកខ្ញុំទៅនៅជាមួយតាផាត ពេទ្យតាផាត កងពលហ្នឹងណា ។

ដានី៖ កងពលតាផាត?

ភួន៖ ហ្នឹងហើយ!

ដានី៖ តាផាត នៅឯណាឥឡូវ?

ភួន៖ តាផាតនៅប៉ៃលិន ។

ដានី៖ គាត់ធ្វើអីដែរឥឡូវ?

ភួន៖ គាត់ឈប់ហើយឥឡូវ ។

ដានី៖ ផ្ទះគាត់នៅណាដែរ?

ភួន៖ ស្រុកកំណើតគាត់ប្រហែលនៅកំពង់ស្ពឺ ប៉ុន្តែប្រពន្ធគាត់នៅស្រុកនេះដែរ ។

ដានី៖ តែគាត់នៅប៉ៃលិន ឥឡូវផ្ទះគាត់នៅម្តុំណាតាផាត?

ភួន៖ នៅប៉ៃលិន មិនដឹងថានៅម្តុំត្រង់ណាទេ ប៉ុន្តែខ្ញុំដឹងថាផ្ទះគាត់មួយនៅក្នុងផ្សារ ប៉ុន្តែគាត់ចេញទៅនៅខាងក្រៅ ផ្ទះនោះជួលឲ្យគេ តែមិនដឹងហៅម្តុំអី ខ្ញុំមិនដែលទៅដល់ទេ អាផ្ទះក្រោយនោះ ។

ដានី៖ តាផាតឈ្មោះគាត់ពេញ ឈ្មោះអីទៅ?

ភួន៖ ឈ្មោះ ផាត ដឹងស្អីផាតទេ ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអី?

ភួនៈ ឈ្មោះ លី ។

ដានីៈ ដល់ពេលឆ្នាំ៨៥ ដល់ពេលយួនវ៉ៃយកសំឡូតបាន កាលហ្នឹងយ៉ាងម៉េច ដូចថាអ្នកនៅសំឡូត...

ភួនៈ កាលខ្ញុំចេញទៅហ្នឹងអត់ទាន់វ៉ៃបានទេសំឡូត វាបុកម្ដង បុកកាលឆ្នាំ៨៤ហ្នឹង បុកយកព្រំដែនទូទៅហ្នុង តែសំឡូតអត់បានទេ កាលហ្នុងព្រំដែនយួនយកបានទាំងអស់ តែសំឡូតមួយយួនយកអត់បានវ៉ៃបកយកវិញបាន បុកមួយសារក្រោយទៀត ដល់ខ្ញុំចេញទៅនោះផុតទៅ ឮថាបុកយកបាន ។

ដានីៈ ដល់បុកយកបានដល់យើងប្រជាជនកងទ័ពអីទៅនៅឯណាវិញ?

ភួនៈ កងទ័ពនៅតាមជាយដែនដដែល តែប្រជាជនចូលក្នុងជំរំកាលហ្នុង ។

ដានីៈ ជំរំអីគេ?

ភួនៈ ជំរំសាយយេ ខ្ញុំទៅដល់នោះហើយ ខ្ញុំអត់ដឹងទេណា បងមឿន គាត់នៅហ្នឹង គាត់នៅហ្នឹងរហូត គាត់ថា គាត់ចូលសាយយេ ចូលអីមក ខ្ញុំដាច់រយៈហើយកាលហ្នឹង ។

ដានីៈ ចុះតាទិត គ្រួសារគាត់ តាជន គ្រួសារគាត់ទៅនៅឯណាវិញ?

ភួនៈ ពេលហ្នឹងបែបនៅជុំគ្នាតាមមើលព្រោះខ្ញុំអត់សូវដឹងដែរ ខ្ញុំទៅមុនដែលគេយកបាន ដាច់ព្រំដែននៅភ្នំដងរែក ។

ដានីៈ ដូចថាឆ្នាំណាដូចយើងយកបានសំឡូតវិញ?

ភួនៈ យកបានសំឡូតវិញឆ្នាំ៨០ប៉ុន្មានទេ អត់ដឹងទេឆ្នាំនោះ ខ្ញុំអត់ដែលមករហូតដល់ឆ្នាំ៩០ជាងបានខ្ញុំមក ។

ដានីៈ ឆ្នាំ៩០ប៉ុន្មានបានពូចូលដល់សំឡូត?

ភួនៈ ខ្ញុំ ៩១ បានខ្ញុំចូលដល់ហ្នុងវិញ ។

ដានីៈ ឆ្នាំ៩១ ចូលដល់សំឡូតយ៉ាងម៉េចដែរ?

ភួនៈ ទៅឃើញផ្សារ ឃើញថៃអីពេញអស់ហើយនៅបរឡាង មកដល់សំឡូតហ្នុងវិញ ។

ដានីៈ កាលហ្នុងអ្នកគ្រប់គ្រងនៅសំឡូតពីណាគេ?

ភួនៈ អ៊ំទិត ។

ដានីៈ ទិត គាត់គណៈស្រុកនៅហ្នុង?

ភួនៈ បាទ! គាត់គ្រប់គ្រង់មួយមុខសញ្ញានៅហ្នុង ជីត្បូងហ្នុងណា មុខសញ្ញាសំឡូត ។

ដានីៈ ចុះតាជន?

ភួនៈ វាផ្នែកៗកាលហ្នុង តាដន គាត់គ្រប់គ្រងដែរ បើតាមខ្ញុំដឹង ដែលខ្ញុំសួរៗ តែវាមិនជាការពិតបានទេណា តាដន គាត់ទទួលខាងលក់ឈើឲ្យថៃ តាទិត គាត់ទទួលផ្នែកខាងត្បូង មានផ្នែកទៀតកាលហ្នឹងបើតាមខ្ញុំស្តាប់ ប្រហែលៗជាអីចឹងមែន។

ជានីៈ ពូទៅឆ្នាំ៩១!

ភួនៈ បាទ! ខ្ញុំទៅឆ្នាំ៩១ហើយ ខ្ញុំទៅ ទៅធ្វើអាហ្នឹងឲ្យអ៊ំទិតដែរទេ ទៅធ្វើគុធ្វើអី ទៅលេងឪពុកម្តាយខ្ញុំដល់ទៅហ្នុងគាត់ឲ្យធ្វើគុធ្វើអីហ្នុងឲ្យគាត់ទៅ ធ្វើគុ ធ្វើសាឡុងឲ្យគាត់បាន មួយរយៈពេលខ្ញុំត្រឡប់មកវិញមក។

ជានីៈ ដល់ឆ្នាំណាបានពូត្រឡប់មក?

ភួនៈ ខ្ញុំទៅបានតែប៉ុន្មានខែ តែ២ខែ ខ្ញុំត្រឡប់មកវិញមក។

ជានីៈ ពូត្រឡប់មកណា?

ភួនៈ ខ្ញុំត្រឡប់មកស្រុកវិញ មកផ្ទះវិញ ខ្ញុំទៅតែខ្ញុំទេ ប្រពន្ធកូននៅនេះទាំងអស់។

ជានីៈ ចុះពូរៀបការឆ្នាំណា?

ភួនៈ ខ្ញុំការឆ្នាំ៨៦ បានកូន២ឆ្នាំ៩០ខ្ញុំវិញមកស្រុកតាមមាតុភូមិនិវត្តន៍ ឆ្នាំ៩១ខ្ញុំឡប់ទៅវិញមួយសារទៀត ខ្ញុំទៅតែខ្ញុំទេ ខ្ញុំទៅរកមើលដីធ្លីនៅណា ព្រោះចិត្តខ្ញុំចង់ទៅនៅបវិល តែខ្ញុំទៅរកបងប្អូន នៅបវិល រកអត់ឃើញខ្ញុំហួសដល់ខ្លែម បានចេញពីខ្លែមទៅខ្ញុំកាត់ទៅរកអ៊ំទិតនៅសំឡូតដើររក។

ជានីៈ ពូទៅដល់ខ្លែមដែរអីចឹង?

ភួនៈ បាទ! ទៅដល់ខ្លែម ធ្លាក់ដល់ទៅចូលជំរំមួយសារទៀត ចូលទៅកាលហ្នុងជំរំសាយអេកមិនទាន់អស់មនុស្សឯណាកាលហ្នុង ចូលទៅលេងបានមួយសារទៀត បានទៅសំឡូត។

ជានីៈ កាលហ្នុងពូទៅម្នាក់ឯង ទៅដល់សំឡូតហើយ ម៉េចបានអត់ចង់នៅសំឡូត ត្រឡប់មកស្រុកវិញ?

ភួនៈ វាចង់ធុញទ្រាន់ព្រៃហើយ គេបបួលខ្ញុំធ្វើទាហានវិញ ខ្ញុំអត់ធ្វើ ជួបពួកមេចាស់ៗហ្នឹង បបួលថានៅធ្វើទាហានហ្នឹងវិញ ខ្ញុំថាអត់ទេ ធ្វើទាហានហ្នឹងវាវេទនាពេកហើយ វេទនាខ្លាំងបំផុតនៅដងរែក។

ជានីៈ កាលពូរៀបការនៅឆ្នាំ៨៦ រៀបការនៅឯណាទៅ?

ភួនៈ នៅដងរែក។

ជានីៈ នៅដងរែក!

ភួនៈ បាទ!

ដានីៈ ចុះប្រពន្ធគាត់ធ្វើអីដែរកាលនៅជងវែក?

ភួនៈ អត់ធ្វើអីផង ពីដើមខ្ញុំទៅឆ្នាំ៨៥ ខ្ញុំនៅជងវែក ដល់ដើមឆ្នាំ៨៦ កាលហ្នុងគេនៅក្នុងជំរំណា នៅជំរំសាយអេកហ្នុង ចេញពីហ្នុងទៅគេស្វែងដើររកបងប្អូននៅជងវែក ដល់ទៅជួប..

ដានីៈ រៀបការបណ្តោយ!

ភួនៈ បាទ!

ដានីៈ ឪពុកម្តាយដឹងអត់កាលរៀបការ?

ភួនៈ ឪពុកម្តាយខ្ញុំនៅហ្នឹងទាំងអស់កាលហ្នឹង ។

ដានីៈ នៅជងវែកទាំងអស់គ្នា?

ភួនៈ បាទ! នៅហ្នឹងជុំគ្នារហូតដល់ឆ្នាំ៨៨ ឆ្នាំ៨៩បានឪពុកម្តាយខ្ញុំគាត់មករកបងគាត់ មកនៅជាមួយបង គាត់វិញណា ។

ដានីៈ នៅជាមួយតាទិត!

ភួនៈ បាទ!

ដានីៈ ប្រពន្ធគាត់អ្នកស្រុកណាដែរ?

ភួនៈ អ្នកស្រុកនេះដែរ ។

ដានីៈ នៅភូមិហ្នឹងដែរ?

ភួនៈ បាទ! ភូមិត្រពាំងសោម ។

ដានីៈ ឃុំត្រពាំងធំ...

ភួនៈ បាទ! ឃុំជាមួយគ្នា ។

ដានីៈ ឃុំត្រពាំងធំខាងត្បូងជាមួយគ្នា?

ភួនៈ បាទ!

ដានីៈ ចុះនៅសំឡូតគេចូលសមាហរណកម្មជាមួយរដ្ឋាភិបាលឆ្នាំណាទៅ?

ភួនៈ ប្រហែលឆ្នាំ៩៧ វាចូលហ្នុងខ្ញុំទៅលេងមួយសារទៀតហើយ ទៅលេងឪពុកម្តាយខ្ញុំហ្នឹង ខ្ញុំរត់ហ្នឹងគេ និងឯងដែរ ឆ្នាំ៩៦ ទៅដល់ហ្នុងទទួលគេវៃគ្នាមួយសារទៀត វៃគ្នាហ្នុងឪពុកម្តាយខ្ញុំគាត់ទៅថៃទៅ ខ្ញុំត្រឡប់ក្រោយវិញមក ខ្ញុំអាងខ្លួនមួយ ខ្ញុំយកប្អូនខ្ញុំមួយមក ប្អូនស្រីខ្ញុំវាមានប្តីមានកូនទៅនោះ ពិបាក ខ្ញុំនាំវាមករហូតឆ្នាំនោះឆ្នាំ៩៧ហើយ ឆ្នាំគេវៃគ្នាហ្នុង... ។

ដានីៈ ដល់ក្រោយមកយើងចាប់ផ្តើមសមាហរណកម្មជាមួយរដ្ឋាភិបាល តាទិត គាត់...

ភួនៈ	គាត់មកមុន គាត់មកអាគេរ៉ៃត្នាហ្នឹង គឺគាត់បណ្តោះខ្លួនចេញមកមុន ។

ដានីៈ	មកណាមុន?

ភួនៈ	មកក្នុងស្រុកនេះមុន ។

ដានីៈ	អូ! មកក្នុងស្រុក!

ភួនៈ	ពីដើមគេប្រុងចាប់គាត់ គាត់ហ្នឹងជាប់គុកម្តងហើយ តាម៉េតចាប់ដាក់គុកកាលពីឆ្នាំ ៨០ជាង ម្តង ។

ដានីៈ	ម៉េចបានតាម៉េតចាប់?

ភួនៈ	មិនដឹងខ្ញុំ បញ្ហាគេតតូតតាំងពីដើមមកបញ្ហាទំនាសគ្នាហ្នឹងណា ពីដើមគាត់ មើលខ្ញុំនិយាយសារដើមវិញ គាត់មានតាដាត ប្រធានកងពលហ្នុងវាសាច់ឈាមខាងប្រពន្ធណា ប្រពន្ធគាត់សាច់ឈាមជាមួយអ៊ីទិតណា តាដាតហ្នឹង ហើយគាត់ជាប្រធានកងពលផង ដល់ពេលវាបញ្ហាតាម៉េតគាត់រកឿង គាត់មិននៅខ្លួច តាដាតមិនមេទាហាននៅខ្លួចទាហានដែរ តាទិត គាត់អត់មានទាហានទេ គាត់ខាងសេដ្ឋកិច្ច គាត់ខាងអីចឹងទៅណា ។

ដានីៈ	ខាងស៊ីវិល!

ភួនៈ	បាទ! ខាងស៊ីវិល ។ គាត់ទាហាន បានដកតាដាតហ្នុងទៅនៅដងរែកទៅ បានឲ្យតាទិត ហ្នឹងអស់ទាហាន អស់មានអំណាចអី តាម៉េត គាត់ក្រឡុកចាប់តាម៉េតដាក់គុក ។

ដានីៈ	ចាប់អីចឹងអត់ខ្លាចតាម៉ុកទេ ព្រោះតាម៉ុកត្រូវបងប្អូនតាទិតដែរ?

ភួនៈ	វាមិនដឹងអាម៉េចកាលហ្នឹង ក្រោយមកបានខ្ញុំដឹងថា គាត់ជាប់គុក២០ថ្ងៃ គាត់និយាយប្រាប់ខ្ញុំគាត់ថា ទៅនោះអត់ដឹងទេ អញគេចាប់ដាក់គុកម៉ា២០ថ្ងៃ តាម៉េតរកឿង គេចោទថាអញអីចេះអញ អីចុះ កាលនោះខ្ញុំទៅដល់នោះហើយខ្ញុំអត់ដឹង ។

ដានីៈ	ចុះឈ្មោះដាត ប្រធានកងពលហ្នុងត្រូវសាច់ឈាមយ៉ាងម៉េចជាមួយតាទិត?

ភួនៈ	ខាងប្រពន្ធ!

ដានីៈ	ខាងប្រពន្ធពីណា?

ភួនៈ	ប្រពន្ធតាដាត! ប្រពន្ធតាដាត អ្នកស្រុកនេះដែរ ។

ដានីៈ	អីចឹងប្រពន្ធតាដាតត្រូវជាបងប្អូនយ៉ាងម៉េចជាមួយតាទិត?

ភួនៈ	ជីដូនមួយ!

ដានីៈ	ជីដូនមួយតាទិត?

ភួនៈ	បាទ!

ដានី៖ ជីដូនមួយហ្នឹងគាត់ជាប់ខ្សែខាងណា គាត់ជាប់ខ្សែខាងតាម៉ុកដែរអត់ទេប្រពន្ធតាផាតហ្នុង?

ភួន៖ អត់ទេ!

ដានី៖ យ៉ាងម៉េចប្រពន្ធហ្នុង?

ភួន៖ មើលខ្សែប្រឡាយហ្នុងចង់ដាច់ដែរ ខ្ញុំអត់សូវចាំច្បាស់ទេ បើបងនឿន គាត់ចាំច្បាស់រឿងហ្នឹង បងនឿនហ្នឹងក៏គាត់ខ្សែស្រឡាយជាមួយខ្ញុំដែរ ។

ដានី៖ ត្រូវជាម៉េចជាមួយពូ?

ភួន៖ បងនឿន ហីខ្ញុំនេះត្រូវជាជីទួតមួយ ។

ដានី៖ ជីទួតមួយ!

ភួន៖ បាទ! ម្ដាយខ្ញុំ ហីម្ដាយគាត់ជីដូនមួយ ។

ដានី៖ អីចឹងគាត់ត្រូវជាម៉េចជាមួយតាទិតដែរ?

ភួន៖ គាត់ត្រូវជាក្មួយដែរ ប៉ុនក្មួយជីដូនមួយ ក្មួយជីទួតអីចឹងទៅណា បើយាយហីនិងយាយ ហ្នឹងពោះមួយ យាយខ្ញុំនិងយាយគាត់ហ្នឹង បើតាមខ្ញុំដឹងយាយហ្នឹងគាត់បងប្អូន៨នាក់ ហើយនៅក្នុងស្រុកនេះទាំងអស់គាត់ហ្នុង ៨នាក់មិនតិចទេ បង្កើតៗដល់ជីដូនមួយ ជីទួតមួយមិនតិចទេ មនុស្ស ច្រើនណាស់ ។

ដានី៖ ចុះតាទិតគាត់ចូលជាមួយរដ្ឋាភិបាលឆ្នាំណាពូមានដឹងទេ?

ភួន៖ ឆ្នាំហ្នឹង ឆ្នាំគេវ៉ៃបរឡាងមួយសារហ្នឹង ដូច៩៧ បើមិន៩៧ ចុងឆ្នាំ៩៦ ដែលខ្ញុំចាំបាន ឆ្នាំខ្ញុំទៅលេងពុកខ្ញុំហ្នឹងហើយ ខ្ញុំឡើងមកទិញសម្ភារៈឈើហ្នឹងថាប្រុងទៅធ្វើនៅហ្នុងណា ដល់ទៅជួបទ័ពគេកំពុងរៀបចំនៅអូរថគ្រោះហ្នុង គេប្រជុំគេអីហ្នុង បានខ្ញុំទៅដល់បរឡាង បានឃើញអ៊ំទិតហ្នឹងគាត់ រៀបចំជិះអាត្រាក់មកខាងក្នុងបាត់ហើយ គេអត់ទាន់វ៉ៃទេទ័ព ដល់គាត់ចេញមកក្នុងផុតបានគេចាប់ ផ្ដើមប្រសេកប្រសាចពេញហ្នុង ។

ដានី៖ ពេលដែលគាត់ចូលជាមួយរដ្ឋាភិបាល គាត់មានតួនាទីអីដែរកាលហ្នុង?

ភួន៖ ខ្ញុំអត់ដឹង! រឿងហ្នុងខ្ញុំអត់ដឹង អត់ដឹងតួនាទីគាត់ចូលមក ។

ដានី៖ គាត់នៅឯណាកាលចូលមក ដូចថាកងទ័ពនៅណា?

ភួន៖ គាត់ចូលមកផុតដល់ភ្នំពេញកាលហ្នុង ។

ដានី៖ ភ្នំពេញ!

ភួន៖ បាទ!

ដានី៖ មកនៅកន្លែងណានៅភ្នំពេញ ។

ភួនៈ គាត់ទិញផ្ទះមួយនៅម្តុំផ្សារមាន់អាំង ។

ដានីៈ ហើយ!

ភួនៈ ហើយបានលក់ផ្ទះហ្នឹងវិញ ។

ដានីៈ លក់ផ្ទះផ្សារមាន់អាំងទៅនៅឯណាវិញ?

ភួនៈ គាត់នៅផ្ទះជួលទម្រាំរកទិញដីបាន ។

ដានីៈ សព្វថ្ងៃគាត់នៅឯណា ផ្ទះគាត់នៅភ្នំពេញ?

ភួនៈ ផ្ទះគាត់នៅភ្នំពេញថ្មី ។

ដានីៈ ភ្នំពេញថ្មី នៅម្តុំណាទៅ?

ភួនៈ ខ្ញុំវាភ្លេចម្តុំកណា និយាយទៅវានៅជាប់ទំនប់ទួលគោក ។

ដានីៈ ជាប់ទំនប់ទួលគោក!

ភួនៈ បាទ! ចុះពីទំនប់ហ្នឹង ខ្ញុំដើរ ជិះមូតូអីទៅ ចុះតាមប្រលោះផ្ទះល្វែង វាមានច្រកខ្លួនហែមមួយ ចុះសំដៅបឹងមួយយើងទៅពីពេទ្យលោកសង្ឃនៅឆ្វេងដៃ ។

ដានីៈ នៅជិតហ្នឹងដែរអីចឹង?

ភួនៈ បាទ! នៅជិតទេ ថាចុះមកប្រហែល១៥០ម៉ែត្រទេផ្ទះគាត់ ។

ដារ៉ាៈ កន្លែងច្រកចូលហ្នឹងមានស្អីជាចំណាំ?

ភួនៈ ផ្ទះល្វែងគេធ្វើសង់ខាងច្រកមួយប្រលោះផ្ទះល្វែងមួយចុះមកក្រោមមក ។

ដារ៉ាៈ កូនគាត់រៀននៅភ្នំពេញហ្នឹងឈ្មោះអី?

ភួនៈ ឈ្មោះពៅ (ស្រី)

ដារ៉ាៈ ស្អីពៅ?

ភួនៈ ហ្អូ! មិនដឹងគេយកត្រកូលអីទេ អត់សួរយកត្រកូលឪជាក់ផង ។

ដានីៈ កូនស្រីគាត់នៅភ្នំពេញហ្នឹងរៀននៅមហាវិទ្យាល័យមួយណា?

ភួនៈ ប្រហែលជាបាក់ទូក កូនស្រីហ្នឹង ឆ្នាំទី៤ហើយ ។

ដានីៈ ពូមានប្រសាន់មុនហ្នឹងម៉េចថាសាលាអីសកលវិទ្យាល័យភូមិន្ទភ្នំពេញ?

ភួនៈ ហ្នឹងកូនខ្ញុំ

ដានីៈ ហ្នឹងកូនលោកពូ!

ភួនៈ បាទ!

ដានីៈ ដល់កូនតាទិត គាត់នៅ...

ភួនៈ ប្រហែលជាសាលាបាក់ទូក មហាវិទ្យាល័យស្អីគេទេ គេប្រាប់ខ្ញុំដែរ ប៉ុន្តខ្ញុំភ្លេចហើយ ។

ដារ៉ាៈ ចុះកូនពូឈ្មោះអីគេរៀននៅភូមិន្ទភ្នំពេញហ្នុង?

ភួនៈ ឈ្មោះ ចាន់ធី ។

ដារ៉ាៈ អីចាន់ធី!

ភួនៈ ផន ចាន់ធី ។

ដារ៉ាៈ រៀននៅសកលវិទ្យាល័យភ្នំពេញ?

ភួនៈ បាទ!

ដានីៈ ផ្នែកខាងអីគេ?

ភួនៈ គេរៀនខាងគណិត ។

ដានីៈ គ្រូគណិត?

ភួនៈ បាទ!

ដារ៉ាៈ ឆ្នាំទីប៉ុន្មានពូ?

ភួនៈ ឆ្នាំទី១

ដារ៉ាៈ ទើបឆ្នាំទី១ទេ!

ភួនៈ បាទ!

ដារ៉ាៈ ទើបហ្នឹងទៅដែរអីចឹង?

ភួនៈ បាទ! ទើបទៅ វាទំនេរមួយឆ្នាំ វាជាប់តាំងពីឆ្នាំទៅ វាអត់បានរៀន ។

ដានីៈ តាទិត គាត់ភាគច្រើនគាត់នៅភ្នំពេញ ឬនៅឯណារាល់ថ្ងៃ?

ភួនៈ តាំងពីប្រូតមកគាត់ទៅនៅនោះរហូត ។

ដានីៈ គាត់នៅឯណាទៅ?

ភួនៈ នៅផ្លូវមាស ។

ដានីៈ បាទ! នៅឯណា នៅផ្លូវមាស!

ភួនៈ ភូមិផ្លូវមាស សេកសក ណា ។

ដានីៈ គាត់នៅចំការគាត់ឬ?

ភួនៈ បាទ! នៅចំការ ។

ដានីៈ ចំការគាត់ ចំការអីទៅ?

ភួនៈ ចំការគាត់វាមានដំណាំច្រើន ។

ដានី៖ ដំណាំអីខ្លះពូដែរ...

ភួន៖ ដាំគាវ៉ែន ច្រើនតែគាវ៉ែន ហឹស្វាយ ។

ដានី៖ ដាំស្វាយ...

ភួន៖ ហឹគាវ៉ែន ។

ដានី៖ គាវ៉ែន ម៉េចទៅគាវ៉ែន?

ភួន៖ ផ្លែមៀន មៀនថៃនោះ ។

ដានី៖ អូ! ដាំស្វាយ ដាំមៀនថៃ ហឹដាំអីទៀតចំការគាត់!

ភួន៖ ស្រការនាគ មានម្ទេស មានអី ខែនេះត្រូវទៅបេះម្ទេស ស្រោចម្ទេសជាមួយយាយគាត់នោះ ។

ដានី៖ អូ! ពីរនាក់យាយ!

ភួន៖ បាទ!

ដានី៖ ធំ! ចំការគាត់ប៉ុន្មានហត ពូដឹងទេ?

ភួន៖ ដីគាត់នៅហ្នុងចូលប្រហែល១០ហត្ថ ប៉ុនគាត់ឲ្យគេធ្វើ គាត់នៅតែដីបន្តិចប្រហែល១ហត ២ហត្ថទេ ហើយគាត់ដាំដំណាំវិញល្វាចនៅហ្នឹង ការពារដំណាំចាស់ហ្នឹងផង ដាំណាំយុទ្ធសាស្ត្រហ្នឹងផង យើងដាំអាដំណាំវិលល្វាចក្នុងហ្នឹង ដូចជាម្ទេស ដូចជាអីណា ។

ដានី៖ គាត់នៅតែពីរនាក់តាយាយទេ?

ភួន៖ បាទ!

ដានី៖ ពូធ្លាប់ទៅចំការគាត់ទេ?

ភួន៖ ធ្លាប់ទៅ កាលភ្ជុំទៅហ្នឹងដែរ ។

ដានី៖ អីចឹងពូមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់ទាន់បានសួរនាំទាកទងហ្នឹងជីវិតពូ ឬរឿងរ៉ាវរបស់អ៊ំពូតាទិតអី ពូមានអីចង់បន្ថែមទេ នូវអ្វីដែលខ្ញុំអត់ទាន់បានសួរនាំពូ ។

ភួន៖ អត់មានអីផង!

ដារ៉ា៖ ចុះភូមិដែលថាតាទិតទៅចំការ ភូមិអីគេហ្នុង?

ភួន៖ ភូមិដូវមាស

ដារ៉ា៖ ឃុំអីគេ?

ភួន៖ ឃុំសេកសក ។

ដារ៉ា៖ ស្រុកអីគេ?

ភួនៈ ស្រុករតនៈមណ្ឌល ។

ដារ៉ាៈ អូ! នៅបាត់ដំបង ។

ភួនៈ បាទ!

ដានីៈ ជាប់ព្រំប្រទល់ជាមួយសំឡូត!

ភួនៈ បាទ!

ដានីៈ ជាប់ជាមួយវ៉ៃដែក!

ភួនៈ បាទ! យើងចេញតែពីជៀវ បំបែកជៀវដល់ហើយ ។

ដានីៈ ផ្លូវបែកហ្នឹងមានផ្លូវមួយចូលទៅរផ្លូវមាសហ្នឹងហើយ បានទៅដល់សេកសក!

ភួនៈ បាទ!

ដានីៈ សេកសកហ្នឹងហើយបានមានកាច់ជ្រុងមួយ!

ភួនៈ ដងទង!

ដានីៈ ដងទងហើយ បានឆ្លងស្ពានមកវ៉ៃដែក សំឡូត ។

ភួនៈ បាទ!

ដានីៈ បាទ! អ៊ីចឹងពូខ្ញុំអរគុណច្រើន ដែលបានចំណេះសំណាលជាមួយពួកខ្ញុំទាក់ទងពីប្រវត្តិរបស់ពូ គ្រួសារពូហ្នឹង!

ភួនៈ បាទ!

ដានីៈ បាទ! ខ្ញុំអរគុណច្រើនពូ!